# ជម្ងឺ បូទូលីស៊ីម (Botulism)

ជម្ងឺ បូទូលីស៊ីម ជារោគធ្ងន់ធ្ងរមួយដែលធ្វើឲ្យសាច់ដុំរបស់លោកអ្នកកម្រើកលែងបាន។ វាកើតមានឡើងដោយមេរោគ។ ជម្ងឺ បូទូលីស៊ីម មាន 3 ប្រភេទ :

- ជម្ងឺ បូទូលីស៊ីម ដោយពុលអាហារ
- ជម្ងឺ បូទូលីស៊ីម ក្នុងចំណោមទារក, ហើយ
- ជម្ងឺ បូទូលីស៊ីម តាមរយៈរបួស។

## តើខ្ញុំប្រហែលជាអាចមានជម្ងឺម្យ៉ាងបណ្ដាលមកពីបរិភោគអាហារខូចរបៀបណា ?

បើសិនជាលោកអ្នកបរិភោគអាហារមិនស្អាត, លោកអ្នកអាចមានជម្ងឺ បូទូលីស៊ីម ។ មនុស្សភាគច្រើនចាប់ផ្ដើមឈឺក្នុងកំឡុងពេល 12-36 ម៉ោង។ ប៉ុន្តែជួនពេលខ្លះវាអាចពន្យាដល់ទៅ 2 អាទិត្យ។

បើសិនជាមានមនុស្សច្រើនដែលទទួលទានអាហារដូចគ្នាចាប់ផ្ដើមឈឺ, ម្ហូបអាហារនោះពិតជាមិនស្អាត។ បើសិនជាមានបុព្វហេតុកើតឡើង អាជ្ញាធរសុខភាពនឹងធ្វើការស៊ើបអង្កេត។ វាអាចមានភេរវជនណាមួយ ប្រហែលជាអាចលួចដាក់មេរោគទាំងឡាយនៅក្នុងម្ហូបអាហារនោះ។

## តើអ្នកណាអាចមានជម្ងឺ បូទូលីស៊ីម កើតមានឡើងក្នុងចំណោមទារកដោយរបៀបណា ?

ទារកទាំងឡាយ, ជាពិសេសគឺទារកដែលទើបមានអាយុ 6 ខែ ឬតិចជាងនេះ, អាចមានរោគនេះ ពីម្ហូបអាហារមិនស្អាត ឬល្អងធូលី។ ទារកទាំងឡាយដែលមិនបៅដោះម្ដាយ ហើយនិងទារកទាំងឡាយដែលញ៉ាំទឹកឃ្មុំប្រហែល ជាអាចមានទំនងមានជម្ងឺ បូទូលីស៊ីម ក្នុងចំណោមទារកនេះ។

## តើខ្ញុំប្រហែលជាអាចមានជម្ងឺ បូទូលីស៊ីម តាមរយៈរបួសដោយរបៀបណា ?

បើសិនជាមេរោគចូលទៅតាមកន្លែងរបួស ឬកន្លែងមុត, លោកអ្នកអាចមានរោគនេះ។

## តើជម្ងឺ បូទូលីស៊ីម ជារោគឆ្លងឬ ?

ទេ។ លោកអ្នកមិនអាចទទួលឆ្លងជម្ងឺ បូទូលីស៊ីម ពីមនុស្សដទៃបានទេ។

## តើអាចឲ្យខ្ញុំការពារពីជម្ងឺ បូទូលីស៊ីម ដោយរបៀបណា ?

នៅក្នុងករណីច្រើន, លោកអ្នកអាចការពារពីជម្ងឺ បូទូលីស៊ីម ដោយធ្វើភារកិច្ចទាំងនេះ :

- ជៀសវាងបរិភោគម្ហូបអាហារកំប៉ុងមិនល្អ ឬម្ហូបអាហារខូច,
- លាងជូតមុខរបួសបានល្អិតល្អន់, ហើយ
- កុំឲ្យទឹកឃ្មុំទារកញ៉ាំឲ្យសោះ។

## តើអាការរោគជម្ងឺ បូទូលីស៊ីម យ៉ាងណាដែរ ?

លោកអ្នកប្រហែលជាមាន :

- បញ្ហាភ្នែក, ដូចជាភ្នែកមើលឃើញច្រើនស្រទាប់និងព្រិលហើយនិងត្របកភ្នែកធ្លាក់សំយុងចុះ,
- សំដីនិយាយឡូលៗ,
- មានការពិបាកលេប, ស្ងួតមាត់, ហើយ
- សាច់ដុំទន់ខ្សោយដែលចាប់ផ្ដើមនៅស្មា ឬខាងលើដៃ ហើយរាលចុះមកដងខ្លួនរបស់លោកអ្នក។
- សាច់ដុំសំរាប់ប្រព័ន្ធដកដង្ហើមប្រហែលអាចកម្រើកលែងបាន។ លោកអ្នកប្រហែលជាអាចឈប់ដកដង្ហើមបាន ហើយស្លាប់។

## តើខ្ញុំអាចស្លាប់មកពីជម្ងឺ បូទូលីស៊ីម ឬទេ ?

បាន។ បើសិនជាលោកអ្នកមិនស្វែងរកការព្យាបាលភ្លាមៗទេ, លោកអ្នកប្រហែលជាអាចឈប់ដកដង្ហើម ហើយស្លាប់។

បើសិនជាលោកអ្នកស្វែងរកការព្យាបាលភ្លាមៗ, លោកអ្នកនឹងប្រហែលអាចជាសៀយឡើងវិញបាន។ បើសិនជាសួតរបស់លែងមានចលនា, លោកអ្នកនឹងត្រូវការម៉ាស៊ីនដកដង្ហើមដើម្បីជួយលោកអ្នកដកដង្ហើម។ វាអាចចំណាយពេលច្រើនអាទិត្យ ឬច្រើនខែដើម្បីជាសះស្បើយ។

## តើខ្ញុំធ្វើយ៉ាងណាបើសិនជាខ្ញុំគិតថាមានជម្ងឺ បូទូលីស៊ីម នេះ ?



ទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក ឬមន្ទីរពេទ្យ***ភ្លាមៗ***។ គេប្រហែលជាអាចឲ្យលោកអ្នកនូវថ្នាំពេទ្យពិសេស។ បើសិនជាលោកអ្នកលេបភ្លាមក្រោយពីបានឈឺ, វាអាចបន្ធូររោគសញ្ញារបស់លោកអ្នកបាន។

## សំរាប់ព័ត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC (Centers for Disease Control) សំរាប់ព័ត៌មានជាភាសាអង់គ្លេស :

800-CDC-INFO (800-232-4636)
888-232-6348 (TTY)

ឬទស្សនាគេហទំព័រ : www.bt.cdc.gov/agent/botulism
www.dhs.ca.gov/epo